**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..១៥....សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការចម្រុះលើកកម្ពស់កិច្ចសហប្រតិបត្តិការ កម្ពុជា ~ បង់ក្លាដែស

**********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ និងមាត្រា៣៤ និងបំពេញបន្ថែមមាត្រា៣៤ ថ្មីស្ទួន និងមាត្រា៣៩ ស្ទួន នៃអនុក្រឹត្យ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ ._**

ត្រូវបានបង្កើតគណៈកម្មការចម្រុះលើកកម្ពស់កិច្ចសហប្រតិបត្តិការកម្ពុជា-បង់ក្លាដែស ដែលមានសមាសភាពដូចខាងក្រោម៖



www.pheakdeylaw.com

| | | |
|---|---|---|
| ១- ឯកឧត្តម **ប្រាក់ សុខុន** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២-ឯកឧត្តម **ផៃ ស៊ីផាន** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣-លោកជំទាវ **អ៊ិត សោភា** | អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤-ឯកឧត្តម **សុខ ខាវ៉ាន់** | រដ្ឋលេខាធិការ ក្រសួងរ៉ែនិងថាមពល | សមាជិក |
| ៥-ឯកឧត្តម **ទួន ថាវរៈ** | រដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ៦-ឯកឧត្តម **ភាន ច័ន្ទមេត្តា** | រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៧-ឯកឧត្តម **សុះ មុះសិន** | រដ្ឋលេខាធិការ ក្រសួងធម្មការនិងសាសនា | សមាជិក |
| ៨- ឯកឧត្តម **ហែម វណ្ណឌី** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៩-ឯកឧត្តម **សាន វណ្ណទី** | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០-ឯកឧត្តម **សុខ សុភ័ក្រ្ត** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១-ឯកឧត្តម **កែ គី** | អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១២-លោកជំទាវ **ឃុន រចនា** | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៣-ឯកឧត្តមសាស្ត្រាចារ្យ **ស៊ា ហួច** | អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ១៤-ឯកឧត្តម **ហ៊ាន ម៉ុនឡៀង** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៥-ឯកឧត្តម **មិន ចណ្ឌីណារុធ** | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៦-ឯកឧត្តម **ហ៊ួ ឌុឡី** | អនុរដ្ឋលេខាធិការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៧-ឯកឧត្តម **គឹម សុភ័ណ** | អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៨-ឯកឧត្តម **នុត អ៊ុនវ័ណារ៉ា** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៩-ឯកឧត្តម **អ៊ុន ធឿន** | អគ្គនាយក ក្រសួងទេសចរណ៍ | សមាជិក |
| ២០-ឯកឧត្តមបណ្ឌិត **គិន ភា** | ប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| ២១-ឯកឧត្តម **អ៊ុង រចនា** | អគ្គនាយកនៃអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | លេខាធិការ |

**ប្រការ២ .-**

គណៈកម្មការនេះ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិគ្រោះយោបល់ និងសហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស លើវិស័យនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម សង្គម វប្បធម៌ និងវិស័យដទៃទៀត ដែលមានប្រយោជន៍ទៅវិញទៅមក
- ពិនិត្យការអនុវត្តកិច្ចព្រមព្រៀង និងពិភាក្សាបញ្ហាទាំងឡាយ ដែលអាចកើតមានឡើងពីការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការលើវិស័យនានា
- ប្រជុំជាមួយគណៈកម្មការភាគីបង់ក្លាដែស តាមការព្រមព្រៀងគ្នាជាមុន ដោយឆ្លាស់វេនគ្នាម្តងម្នាក់នៅប្រទេសបង់ក្លាដែសនិងនៅប្រទេសកម្ពុជា



www.pheakdeylaw.com

- សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំឯកសារ កម្មវិធីនៃសកម្មភាព ក្នុងការគ្រប់គ្រង និងជំរុញកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ កម្ពុជា និងបង់ក្លាដែស ក្នុងទិសដៅអាទិភាពនៃវិស័យនានា ដែលបានព្រមព្រៀងគ្នា ដោយរដ្ឋាភិបាលទាំងពីរ
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសុំមតិណែនាំនិងគោលការណ៍សម្រេច
- ទទួលភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល

**ប្រការ៣ .-**

សមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

ក្នុងករណីចាំបាច់ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានដើម្បីដឹកនាំជំនួស។

ក្នុងករណីសមាជិកណាម្នាក់មិនបានចូលរួមប្រជុំ ដោយជាប់រវល់ភារកិច្ច ត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេច ឱ្យចូលរួមប្រជុំជំនួស។

ក្នុងករណីចាំបាច់ ប្រធានមានសិទ្ធិអញ្ជើញអ្នកជំនាញឯកទេស មកពីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ឱ្យចូលរួមប្រជុំ ឬជួយបំពេញការងារ ក្នុងឋានៈជាជំនួយការបច្ចេកទេស។

**ប្រការ៤ .-**

គណៈកម្មការនេះ មានអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាលេខាធិការដ្ឋាន និងមានសិទ្ធិប្រើត្រារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៥ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១ ខែ មីនា ឆ្នាំ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៦
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com